# សេរីភាពមូលដ្ឋាននៅកម្ពុជា៖
# ការវិវឌ្ឍន៍ក្នុងរយៈពេល៧ឆ្នាំ នៃការយល់ឃើញរបស់ថ្នាក់ដឹកនាំសង្គមស៊ីវិល

គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន គឺជាគម្រោងដែលបានធ្វើការឃ្លាំមើលលំហសង្គមស៊ីវិលនៅកម្ពុជាច្រើនឆ្នាំមកហើយ ជាពិសេសឃ្លាំមើលទៅលើលទ្ធភាពរបស់បុគ្គលដែលអាចអនុវត្តសេរីភាពខាងសមាគម សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការជួបប្រជុំ (សេរីភាពមូលដ្ឋាន)។ គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន គឺជាគំនិតផ្តួចផ្តើមរួមគ្នារបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (“ម.ស.ម.ក”) សមាគមសិទ្ធិមនុស្ស និងអភិវឌ្ឍន៍កម្ពុជា (“អាដហុក”) មជ្ឈមណ្ឌលសាមគ្គីភាព និងមជ្ឈមណ្ឌលអន្តរជាតិដើម្បីច្បាប់ដោយមិនយកប្រាក់កម្រៃ (“អាយស៊ីអិនអិល”)។

គោលដៅសំខាន់នៃគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន គឺស្វែងយល់ពីការយល់ឃើញរបស់ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល ថ្នាក់ដឹកនាំសហជីព និងថ្នាក់ដឹកនាំសហព័ន្ធសហជីព អំពីលទ្ធភាពរបស់ខ្លួនក្នុងការអនុវត្តសេរីភាពមូលដ្ឋាន។ ដើម្បីប្រមូលយកព័ត៌មាននេះ ការស្ទង់មតិរបស់ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងថ្នាក់ដឹកនាំសហជីព ត្រូវបានធ្វើឡើងដោយជាមធ្យមមានថ្នាក់ដឹកនាំចំនួន ១៧៥ នាក់ បានចូលរួមការស្ទង់មតិប្រចាំឆ្នាំនីមួយៗនៃគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន។[១]




## ការវិវឌ្ឍន៍សំខាន់ៗសម្រាប់ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព

នៅក្នុងឆាំ២០២២ មានការថយចុះចំនួនថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ដែលឆ្លើយតបថារដ្ឋាភិបាលទទួលស្គាល់អង្គការរបស់ខ្លួនថាជាដៃគូអភិវឌ្ឍន៍ស្របច្បាប់ និងមានសមត្ថភាព។







[១] ឆ្នាំ២០១៦ ចាប់ពីខែមេសា ឆ្នាំ២០១៦ ដល់ខែមីនា ឆ្នាំ២០១៧, ឆ្នាំ២០១៧ ចាប់ពីខែមេសា ឆ្នាំ២០១៧ ដល់ខែមីនា ឆ្នាំ២០១៨។ ឆ្នាំ២០១៨ ចាប់ពីខែមេសា ឆ្នាំ២០១៨ ដល់ខែមីនា ឆ្នាំ២០១៩។ ឆ្នាំ២០១៩ ចាប់ពីខែមេសា ឆ្នាំ២០១៩ ដល់ខែមីនា ឆ្នាំ២០២០។ ឆ្នាំ២០២០ ចាប់ពីខែមេសា ដល់ខែធ្នូ ឆ្នាំ២០២០។ ឆ្នាំ២០២១ ចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០២១។ ឆ្នាំ២០២២ ចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០២២។

ចំនួនថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ដែលរាយការណ៍ថា**រដ្ឋាភិបាលបានតាមដានសកម្មភាពរបស់ខ្លួន** កើនឡើងក្នុងឆ្នាំ២០២២។




ភាគរយថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ដែលឆ្លើយតបថា ការឃ្លាំមើលរបស់រដ្ឋាភិបាលហាក់ហួសហេតុ ក្នុងឆ្នាំ២០២២ គឺថយចុះ ប្រៀបធៀបទៅនឹងឆ្នាំមុនៗ។




ភាគរយថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ដែលរាយការណ៍ថាការបង្កើតបណ្ដាញ សម្ព័ន្ធ សហព័ន្ធ និងសហជីព ត្រូវបានរឹតត្បិត កើនឡើងក្នុងឆ្នាំ២០២២ (៣៤% នៃអ្នកឆ្លើយតបថា ត្រូវបានរឹតត្បិត)។ ការបង្កើតបណ្ដាញ និងសម្ព័ន្ធគឺមានសារសំខាន់សម្រាប់អង្គការសង្គមស៊ីវិល និងសហជីពដើម្បីការសហការរួមគ្នា ដោយធានាថាការអភិវឌ្ឍន៍ត្រូវបានចូលរួមដោយសហគមន៍មូលដ្ឋាន ហើយសិទ្ធិមនុស្សត្រូវបានគោរព ការពារ និងបំពេញ។ តាមរយៈការធ្វើបែបនេះ សង្គមស៊ីវិលអាចទាញយកធនធាន និងជំនាញផ្សេងៗ មកប្រើប្រាស់ ដើម្បីធ្វើការឆ្ពោះទៅរកគោលដៅរួម ឬស្វែងរកដំណោះស្រាយចំពោះបញ្ហា ដែលប៉ះពាល់ដល់សមាជិកសហគមន៍ជាច្រើន។ ដូចគ្នានេះដែរ ការបង្កើតបណ្ដាញមានសារសំខាន់សម្រាប់សហជីពដើម្បីផ្លាស់ប្ដូរព័ត៌មានក្នុងចំណោមសហជីពផ្ទាល់ និងរៀបចំសកម្មភាពរួមដែលអាចឈានដល់បាតុកម្ម ឬដើម្បីបង្ហាញសាមគ្គីភាព។




ចំនួនថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ដែលឆ្លើយតបថា **តម្រូវការផ្ដល់របាយការណ៍មិនមែនហិរញ្ញវត្ថុពីសំណាក់រដ្ឋាភិបាល គឺជាតម្រូវការដែលហួសហេតុ ឬជាបន្ទុកស្មុគស្មាញ** មានការកើនឡើងប្រៀបធៀបទៅនឹងឆ្នាំ២០២១។




ក្នុងឆ្នាំ២០២២ ភាគរយថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ដែលរាយការណ៍ថា "មានសេរីភាព"[២] ក្នុងការអនុវត្តសេរីភាពខាងការបញ្ចេញមតិ ស្ទើរតែមិនផ្លាស់ប្ដូរបើប្រៀបធៀបទៅនឹងឆ្នាំ២០២១ ប៉ុន្តែធ្លាក់ចុះជាលំដាប់ចាប់តាំងពីឆ្នាំ២០១៨ មក។




[២] ចំពោះអ្នកឆ្លើយតបថា "មានសេរីភាព" ក្នុងនោះរួមមានភាគរយអ្នកឆ្លើយតបដែលបានរាយការណ៍ថា"មានសេរីភាពខ្លាំងណាស់" ឬ "មានសេរីភាពខ្លះដែរ" ។

នៅឆ្នាំ២០២២ អ្នកឆ្លើយតប ៨៦% បានឆ្លើយថាខ្លួន *ជានិច្ចកាល ប្រចាំ* ឬ *នៅពេលខ្លះ* តែងរឹតត្បិតខ្លួនឯង ដោយសារតែខ្លាចការសងសឹកពីរដ្ឋាភិបាល។ ភាគរយនេះគឺមានភាពប្រហាក់ប្រហែលគ្នា ក្នុងរយៈពេលដែលគម្រោងចាប់ផ្តើមអនុវត្តចាប់តាំងពីឆ្នាំ២០១៦ មក។ ទោះជាយ៉ាងណាក៏ដោយ ភាគរយអ្នកឆ្លើយតបថា **“ជានិច្ចកាល” តែងរឹតត្បិតខ្លួនឯង** បានបន្តកើនឡើងដល់ ២៤% ក្នុងឆ្នាំ២០២២។




ភាគរយថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ដែលរាយការណ៍ថាចូលរួម **“ញឹកញាប់ណាស់” នៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងដំណើរការតាក់តែងច្បាប់ជាមួយរដ្ឋាភិបាល កើនឡើង ១%។** ភាគរយអ្នកឆ្លើយតបថា **“មិនដែលសោះ”** ក្នុងការចូលរួមដំណើរការសេចក្តីសម្រេចចិត្ត បានធ្លាក់ចុះក្នុងកម្រិតទៀបបំផុត ចាប់តាំងពីគម្រោងបានអនុវត្ត នេះបង្ហាញនូវការចូលរួមរបស់ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព មានចំនួនកាន់តែច្រើនឡើងចូលរួមក្នុងដំណើរតាក់តែងច្បាប់ផ្សេងៗ។ ទោះជាយ៉ាងណាក៏ដោយ ភាគរយរបស់ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ដែលឆ្លើយថាចូលរួម **“ញឹកញាប់”** នៅមានកម្រិតទាបមែនទែន ដោយមានតែ ៦% ក្នុងឆ្នាំ២០២២ និង ១២% ប៉ុណ្ណោះក្នុងឆ្នាំ២០១៩។




ភាគរយថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព រាយការណ៍ថាពុំមានសុវត្ថិភាពក្នុងការចែករំលែកព័ត៌មានតាមប្រព័ន្ធផ្សព្វផ្សាយ ធ្លាក់ចុះមកត្រឹម ១៧% ក្នុងឆ្នាំ២០២២ បន្ទាប់ពីកើនឡើងខ្ពស់ក្នុងឆ្នាំ២០១៩ (ដោយបានកើនខ្ពស់បំផុត ៣៨% នៃអ្នកឆ្លើយតប មុននឹងធ្លាក់ចុះមក ៣៥% ក្នុងឆ្នាំ២០២០ និងបានកើនឡើងបន្តិចមក ៣៦% ក្នុងឆ្នាំ២០២១)។ ទោះបីជាបែបនេះក៏ដោយ ក៏ភាគរយ ដែលថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ជានិច្ចកាលតែងរឹតត្បិតខ្លួនឯងនៅតែមានកម្រិតខ្ពស់ ដោយថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព អាចនឹងមានសុវត្ថិភាពចែករំលែកតែព័ត៌មានដែលចាត់ទុកថាមិនរសើបប៉ុណ្ណោះ ទៅលើប្រព័ន្ធផ្សព្វផ្សាយរបស់ខ្លួន។



ក្នុងឆ្នាំ២០២២ ***២០%*** នៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព បានអះអាងថាធ្លាប់ត្រូវបានគេបដិសេធផ្តល់ព័ត៌មានមិនសំងាត់ និង/ឬមិនរសើប ដែលខ្លួនបានស្នើសុំទៅរដ្ឋាភិបាល រួមមានព័ត៌មានទាក់ទងនឹងច្បាប់ គោលនយោបាយ និងស្ថិតិ។ ច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានគឺចាំបាច់ ព្រោះច្បាប់នេះនឹងជួយធានាឱ្យបានជុំវិញការទទួលព័ត៌មានពេញលេញ សមស្របនឹងស្តង់ដារច្បាប់អន្តរជាតិ ព្រមទាំងការអនុវត្តល្អប្រសើរ។




................ចប់...............

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា Cambodian Center for Human Rights

សមាគមអាដហុក ADHOC

SOLIDARITY CENTER AFL-CIO

BY NC SA

ខែកក្កដា ឆ្នាំ២០២៣